# ការសំភាសន៍របស់បងប្រុស នៅ សឿន

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ នៅ សឿន

## ការសង្ខេបរបស់បងប្រុស នៅ សឿន

បងប្រុស នៅ សឿន មានអាយុ 46ឆ្នាំនៅឆ្នាំ2018 បងប្រុស នៅ សឿន មានភេទប្រុស

បងប្រុស នៅ សឿន មានទីលំនៅបច្ចុប្បន្ន នៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បងប្រុស ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYUហាសបង ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយនឹងដូនតាចឹងហាសបង ហើយនៅពេលដែរខ្ញុំសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ហាសបង ចុះបងយល់ព្រមដើម្បីអោយខ្ញុំដាក់

ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខៈ បាទព្រម

កៈ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍បងគឺនៅថ្ងៃទី3 ខែ2 ឆ្នាំ2018ហាសបង ហើយការសំភាសន៍មួយនេះត្រូវបានធ្វើឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញចឹងហាសបង ចុះសំរាប់ឈ្មោះពេញរបស់បងមានឈ្មោះអីគេដែរទៅបង?

ខៈ ខ្ញុំឈ្មោះ សឿន

កៈ ប៉ុន្តែត្រកូលមានឈ្មោះអីគេដែរទៅបង?

ខៈ ថាម៉េចនាមត្រកូល?

កៈ នាមត្រកូលហាសបង?

ខៈ និយាយឈ្មោះឪហោស

កៈ បាទនឹងហើយបង?

ខៈ ឈ្មោះនៅ សឿន

កៈ ឈ្មោះ នៅ សឿន ហោសបង ចុះមានឈ្មោះហៅក្រៅទេបង
កាលពីនៅតូចនឹងមាននរណាគេហៅបងឈ្មោះអីគេផ្សេងទេបង?

ខៈ ទេអត់មានទេ

កៈ ចុះចឹងអត់មាននរណាហៅឈ្មោះបងអីផ្សេងទេណបង?

ខៈ អត់មានទេមានឈ្មោះ នៅ សឿននឹងហាស

កៈ ចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?

ខៈ អាយុ46ឆ្នាំហើយនឹង

កៈ អាយុ46ឆ្នាំហោសបង ចុះបងកើតនៅថ្ងៃខែឆ្នាំណាបងមានចងចាំទេ?

ខៈ ភ្លេចហើយទាល់តែមានអត្តសញ្ញាណប័ណហោស

កៈ ប៉ុន្តែបងអាយុ46ឆ្នាំណបង?

ខៈ បាទអាយុ46ឆ្នាំ

កៈ ចឹងបងកើតនៅឆ្នាំ1972បង?

ខៈ បាទនឹងហើយ ហាសនិយាយត្រូវទៀតហាស

កៈ ដោយសារតែខ្ញុំដកលេខហើយនឹងហាស ចុះបងឆ្នាំខ្មែរហាស ឆ្នាំជូត ឆ្លូវ ខាល
ថោះហាសបងមានឆ្នាំអគេដែរបង?

ខៈ ខ្ញុំឆ្នាំជូត ឆ្នាំកណ្តុរហោស

កៈ នៅឆ្នាំជូតណបង ចុះបងកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីដែរបង?

ខៈ ខ្ញុំនៅច្រើនខេត្ត

កៈ ប៉ុន្តែកន្លែងដែរបងកើតហាស?

ខៈ ស្រុកកំណើតនៅខេត្តកណ្តាល

កៈ ប៉ុន្តែនៅភូមិអីគេដែរបង?

ខៈ ភូមិព្រៃកតាលាប់ ស្រុកលើកដែកខេត្តកណ្ដាល

កៈ ប៉ុន្តែឃុំអីគេដែរបង?

ខៈ ឃុំអីគេទេនេះភ្លេចឃុំហើយនឹងហាស ស្រុកលើកដែក ឃុំលើកដែក ភូមិព្រៃកតាលាប់ខេត្តកណ្ដាលហាស

កៈ ចុះបងមានបងប្អូនចំនួនប៉ុន្មានដែរបង?

ខៈ ខ្ញុំស្លាប់អស់ហើយនឹងហាស បងប្អូនចំនួន5នាក់

កៈ បងជាកូនទីប៉ុន្មានដែរបង?

ខៈ ខ្ញុំជាបងគេបង្អស់

កៈ បងជាបងគេហោស ចុះមានស្រីប៉ុន្មាន ហើយប្រុសប៉ុន្មានដែរបង?

ខៈ ស្រីបន្ទាប់ខ្ញុំមួយនឹងអានឹងផាត់ចោលទៅ អានឹងងាប់ជំនាន់អាពតហាស នៅសល់តែ4នាក់ទេនេះហាស

កៈ ប៉ុន្តែសរុបទាំងអស់មាន5នាក់ស្រីមាន1នាក់?

ខៈ បាទនឹងហើយ

កៈ ប៉ុន្តែប្រុស4នាក់?

ខៈ ប្រុស4នាក់ ស្រី1នាក់ទាំងអស់7នាក់

កៈ អូ៎!មាន5នាក់ រឺមួយក៏7នាក់ដែរបង?

ខៈ មាន7នាក់ទាំងខ្ញុំនឹងហាស
មីពៅនឹងវាស្លាប់កើតកញ្ជ្រឹលនៅពេលដែរជំនាន់ពលពតហាស

កៈ ប៉ុន្តែបងអាចប្រាប់រៀបរាប់ឈ្មោះបងប្អូនរបស់បងបានទេ?

ខៈ ថាម៉េចដែរ?

កៈ បងអាចប្រាប់ឈ្មោះបងប្អូនរបស់បងថាពួកគាត់មានឈ្មោះអីគេខ្លះបានទេបង?

ខៈ បាទខ្ញុំឈ្មោះ សឿន, សេន, ស៊ុន, ប៉ុន្តែអ្នកស្លាប់នឹងមិនបាច់យកទេហោស?
កៈ រាប់ទាំងអស់មកបង?

ខ៖  រាប់ទាំងអស់តែម្តងហោស

ក៖  ប៉ុន្តែបងមានចងចាំទេ?

ខ៖  ខ្ញុំចាំតា

ក៖  បើចាំបងអាចរាប់ទាំងអស់មកបានទេ?

ខ៖  រាប់ទាំងអស់ខ្ញុំសឿន ម្ចាស់ខ្សែក្រវ៉ាត់ហាស ខ្ញុំសឿន បន្ទាប់មកមីយឿន នឹងស្រី

ក៖  អូ្ហ!យឿនណាបង?
ខ៖  បន្ទាប់មក សេន , ស៊ុន , ហើយសុំ, ស៊ីម, បន្ទាប់មកធី
មើលបានប៉ុន្មាននាក់ដែរហើយនឹង

ក៖  ខ្ញុំភ្លេចបាត់ដែរហើយនឹងហាស?

ខ៖  អូ្ហ!ខ្ញុំភ្លេចដែរ

ក៖  ប៉ុន្តែបងប្អូនរបស់បងមានតែប៉ុណ្ណឹងតាហីបង?

ខ៖  មានច្រើនតា

ក៖  ចុះបងមានចងចាំសាច់រឿងអីជាមួយគាត់ដែរទេ
កាលពីនៅក្មេងៗជាមួយគាត់ធ្លាប់ធ្វើរឺក៏លេងអីជាមួយគាត់ដែរបង?

ខ៖  បាទថាម៉េច?

ក៖  បងធ្លាប់បានធ្វើអីគេខ្លះជាមួយពួកគាត់កាលពីនៅក្មេងៗដែរទេបង?

ខ៖  មិនដែរធ្វើអីផងនឹង

ក៖  ដូចជាបងធ្លាប់មានលេងឡឹកបាយឡ រឺក៏លេងបិទពួនទេកាលបីនៅក្មេងៗហាសបង?

ខ៖  ធ្លាប់លេងឡឹកបាយឡ លេងអីចម្មតាអីនឹង

ក៖  ប៉ុន្តែបងធ្លាប់លេងគប់ឈូស រឺលេងគប់លុយ
រឺលក្ខណះថាលេងឈូសលុយអីបងធ្លាប់បានលេងដែរទេបង?

ខ៖  ខ្ញុំធ្លាប់លេងបាញ់ថុយអីនឹង

ក៖  អូ្ហ! លេងបាញ់ថុយអីហោសបង?

ខ៖  នឹងហើយលេងបាញ់តាងនឹង

កៈ ចុះលក្ខណះថាលេងបាញ់ឃ្លីអីមានលេងទេ?

ខៈ ខ្ញុំលេងតែបាញ់ថុយនឹងហាស ប៉ុន្តែលេងគប់វង្សដាក់លុយអីនឹងហាស

កៈ ប៉ុន្តែបងធ្លាប់លេងបាញ់ឃ្លីអីដែរតាហីបង?

ខៈ ខ្ញុំមិនដែរលេងទេ

កៈ លក្ខណះលេងលោតកំពស់អីហាសបង?

ខៈ ខ្ញុំមិនដែរលេងទេ លេងតែបាញ់ថុយ នឹង

កៈ នឹងលេងគប់វង្សដែរ?

ខៈ នឹងហើយគប់វង្សនឹងហាស លេងបោះស្បែងជើង
ឈានបីទៅប្ដូនជើងអីចឹងទៅណាស់
ប៉ុន្តែអាបាញ់តាងអីចឹងទៅមិនសូវចំណូលទេនឹងហាស

កៈ អូ!បងចូលចិត្តលេងបាញ់ថុយហោសបង?

ខៈ នឹងហើយលេងបាញ់ថុយនឹងហាស នឹងលេងគប់វង្សចឹងទៅណាស់

កៈ ចុះបងចូលចិត្តលេងអីជាមួយបងប្អូនរបស់បងកាលពីបងនៅក្មេងហាស?

ខៈ ចូលចិត្តលេងតែបាញ់ថុយ ហើយនឹងគប់វង្សនឹង

កៈ អូ!បាទបង ចុះអីផ្សេងពីនឹងអត់មានទេ?

ខៈ អត់មានទេ

កៈ ចុះបងប្អូនរបស់បងសព្វថ្ងៃពួកកាត់រស់នៅណាដែរបង?

ខៈ នៅអ្នកលឿងនឹង

កៈ នៅអ្នកលឿង នៅអ្នកលឿងទាំងអស់តែម្ដងហោសបង?

ខៈ បាទនៅអ្នកលឿងនឹងហាស

កៈ ពួកគាត់ធ្វើអីគេដែរបង?

ខៈ ពួកគាត់អ្នកលីជី

កៈ គាត់ជាអ្នកលីជីសំរាប់ចិញ្ចឹមជីវិតណាបង?

ខៈ បាទនឹងហើយ

កៈ អូ!ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ គាត់ស្លាប់បាត់ហើយនឹងហាស

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរបង?

ខៈ គាត់មានឈ្មោះស៊ាន

កៈ ចុះគាត់អាយុប៉ុន្មាន នឹងគាត់កើតនៅឆ្នាំណាបងមានចងចាំទេ?

ខៈ គាត់អាយុ58ឆ្នាំហើយនឹង

កៈ គាត់អាយុ58ឆ្នាំ សំរាប់គាត់ស្លាប់អាយុ58ឆ្នាំ រឺក៏ឥឡូវនឹងគាត់អាយុ58ឆ្នាំ?

ខៈ គាត់ស្លាប់អាយុ58ឆ្នាំនឹង

កៈ ប៉ុន្តែគាត់ស្លាប់ប៉ុន្មានឆ្នាំដែរបង?

ខៈ គាត់ស្លាប់យូរដែរហើយនឹងហាស

កៈ គាត់ស្លាប់នៅឆ្នាំណាបងមានចងចាំទេ?

ខៈ អត់ចងចាំទេភ្លេចបាត់ហើយ ដឹងតែយូរហើយនឹងហាស

កៈ ភ្លេចបាត់ហោសបង?

ខៈ គាត់ស្លាប់នៅឆ្នាំប៉ុន្មានទេនេះ

កៈ មុនពលពតរឺមួយក៏នៅជំនាន់ពលពតដែរបង?

ខៈ ខ្ញុំមិនទាន់ដល់ទេ គាត់ស្លាប់នៅឆ្នាំ2016នឹង

កៈ ចឹងគាត់ទើបតែស្លាប់នឹងទេចឹង?

ខៈ គាត់ស្លាប់យូរហើយនឹង

កៈ អូ!យូរហើយបង?

ខៈ បើខ្ញុំមិនដែរចេះដឹងអាចឹងផងនឹង

កៈ អូ!អត់អីទេ ចុះម្ដាយរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ ម្ដាយរបស់ខ្ញុំមានឈ្មោះ យាន

កៈ គាត់ឈ្មោះយាន ចុះគាត់អាយុប៉ុន្មានបងមានចងចាំទេ?

ខ៖  គាត់អាយុ72ឆ្នាំហើយនឹង

ក៖  គាត់អាយុ72ឆ្នាំហោសបង
ចុះឪពុករបស់បងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតហាសបង កាលពីគាត់នៅរស់ហាស?

ខ៖  គាត់លីសែងបាយកក់ បាយក្តាំងចិញ្ចឹមកូននឹងហាស

ក៖  ចុះគាត់ជាមនុស្សស្លូតរឺមួយក៏កាច់ដែរបង?

ខ៖  យ៉ាប់ហាសចាស់ៗកាលពីជំនាន់ណុងហាស
និយាយទៅចាស់ៗកាលណុងវារៀងកាច់សាហាវបន្តិចនឹង

ក៖  អូ៎!កាចហោសបង?

ខ៖  មិនមែនដូចក្មេងៗសម័យឥឡូវនឹងចេះអោនលំទោន

ក៖  អូ៎!ចឹងហោសបង?

ខ៖  កាត់ដូចថារៀងកាច់ដែរកាលពីចាស់ៗបីដើមហាស
កាលពីចាស់នៅឥឡូវនឹងដូចមិនដូចក្មេងសម័យឥឡូវហាស

ក៖  អូ៎!បាទបងបាទ?

ខ៖  បើល្មមៗនឹងត្រូវចោលៗ ត្រូវគប់ៗហើយនឹងហាស មិនធម្មតាទេបង
ខ្ញុំនិយាយចឹងតែម្តងនឹង បើបងឯងខឹងខ្ញុំក៏ខឹងទៅណាស់

ក៖  អត់អីទេបង?

ខ៖  ខ្ញុំធំល្មត់ទុំទៅលើបងឯងបន្តិចហើយណាស់

ក៖  បាទមិនអីទេនឹង ចុះម្តាយរបសបងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖  ម្តាយរបស់ខ្ញុំនឹងកាលពីមុនគាត់លក់ពោត

ក៖  អូ៎!លក់ពោតហោសបង?

ខ៖  បាទកាលពីគាត់ចាប់កំណើតនឹងមកគាត់លក់ពោតនឹងតែម្តង
លក់ពោតនៅក្បែរសាលាអ្នកលឿនហាស

ក៖  បាទល្អហើយបង?

ខ៖  នឹងហើយស្មោរទាំងខ្វះៗដើម្បីចិញ្ចឹមកូន

កៈ ចុះម្ដាយរបស់បងគាត់ស្លូតរឺមួយក៏កាច?

ខ ម្ដាយរបស់ខ្ញុំគាត់ស្លូតទេ

កៈ ម្ដាយរបស់បងស្លូតហោសបង?

ខៈ បាទមិនដែរជេរកូន រឺក៏មិនដែរថាអោយកូនអីទេនឹងហាស

កៈ ចុះកាលពីបងនៅជាមួយឪពុកម្ដាយរបស់បងហាស
បងធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេបង
រឺមានការសប្បាយអីជាមួយពួកគាត់ដែរទេ?

ខៈ និយាយទៅជាមួយឪពុករបស់ខ្ញុំនឹងហោស

កៈ ទាំងឪពុកទាំងម្ដាយហាស បងមានចងចាំអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេបង?

ខៈ ខ្ញុំមានរកម្មរកុះនឹង ឪពុកគាត់ចេះតែរករឿងម្ដាយចឹងហាស
ដល់ពេលដែរគាត់ហូបចឹងចេះតែរករឿងកូននឹងរករឿងចៅចឹងហាស

កៈ អូ៎!បាទបងត្រូវហើយបង?
ខៈ ហើយអាកូនចេះតែពិបាកចិត្តចឹងហាស

កៈ ប៉ុន្តែបងមានពេលដែរសប្បាយអីជាមួយពួកគាត់ដែរទេ
ដូចជាទៅស្រែជាមួយបួកគាត់អីដែរចឹងហាស?

ខៈ អត់មានពេលសប្បាយទេនឹងហាស កាលពីគាត់នៅនឹងគ្មានដែរសប្បាយទេនឹង
គាត់តែងតែផឹកស្រារករឿងរហូតនឹងហាស

កៈ អូ៎!ចឹងហោសបង?

ខៈ និយាយរួមទៅមានតែភាពជូចត់នឹង

កៈ
ចុះឪពុកម្ដាយរបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់ពួកគាតកាលពីគាត់នៅក្មេងៗទៅបងដែរទេបង ដូចថាគាត់ធ្លាប់ធ្វើការអីគេ ហើយគាត់ធ្លាប់រកស៊ីអីគេចឹងហាស?

ខៈ គាតធ្លាប់រកស៊ីដូចថាជីកដី ដាក់ថ្មល់ រឺមួយដាក់ត្រណុបអីចឹងហាស
ដូចថាថ្នល់អីចឹងហាស
ពេលក្រហុកអីនឹងគាត់ជីកដាក់ទយលទាបអីចឹងហាសអោយឡានបើកបរអីបានល្អចឹងហាស

កៈ ចុះយាយតាខាងឪពុកបងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ បាទថាម៉េចដែរ?

កៈ យាយតាខាងឪពុកបងមានស្គាល់ឈ្មោះគាត់ដែរទេបង?

ខៈ ខាងឪរបស់ខ្ញុំនឹង

កៈ បាទបងមានស្គាល់ឈ្មោះគាត់ដែរទេបង?

ខៈ គាត់ឈ្មោះម៉ៅសុខ

កៈ នឹងឈ្មោះ តាម៉ៅ យាយសុខហីបង?

ខៈ នឹងតារបស់ខ្ញុំឈ្មោះម៉ៅ ឯយាយរបស់ខ្ញុំឈ្មោះសុខ

កៈ អូ្!ដោយសារតែបងហៅម៉ៅសុខចឹងខ្ញុំអត់ដឹងទេ
ចុះយាយតាខាងម្ដាយវិញបងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ឈ្មោះនៅ សុំ

កៈ ឈ្មោះតានៅ យាយសុំ

ខៈ នឹងហើយដូចថាខ្ញុំប្រាប់ម៉េចចឹងហាស

កៈ ចុះបងមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅបង?

ខៈ ខ្ញុំមកនៅជិត40ឆ្នាំហើយនឹងហាស

កៈ អូ្!បងមកនៅទីនេះយូរដែរហើយហោសបង?

ខៈ មកនៅយូរដែរហើយ

កៈ ប៉ុន្តែបងអត់ទាន់មានកូនចៅទេណាបង?

ខៈ មានតាមានកូន4នាក់

កៈ អូ្!មានកូន4នាក់ហោសបង?

ខៈ បាទបង

កៈ ប៉ុន្តែពួកគាត់មានធ្លាប់ទៅរស់នៅក្រៅប្រទេសងីទេបង?

ខៈ អត់មាន

កៈ ដូចជាមានធ្លាប់ទៅធ្វើការនៅថៃ នៅវៀតណាម រឺមួយនៅកូរ៉េអីទេបង?

ខៈ បងប្អូនរបស់ខ្ញុំឧស្សាហ៍ទៅថៃ ទៅបាំងកកអីដែរតាបងប្អូនហាស

កៈ ប៉ុន្តែបងប្អូនមាន?

ខៈ មានតានឹង បងប្អូនឧស្សាហ៍ទៅបាំងកកអីចឹងហាស

កៈ បាទបងបាទនឹងហើយ

ខៈ ប៉ុន្តែសំរាប់ខ្ញុំអត់ដែរបានទៅទេ

កៈ ប៉ុន្តែកូនអត់ដែរបានទៅទេណា?

ខៈ បងប្អូនមានត្រូវទៅ ទៅបាំងកកអីចឹងហាស

កៈ ប៉ុន្តែបើប្អូនមាន ប៉ុន្តែពួកគាត់ធ្វើអីគេនៅបាំងកកដែរបង?

ខៈ គាត់ទៅធ្វើខាងអាគុយ

កៈ អូ្!គាត់ទៅធ្វើការងារនៅណុងហោសបង?

ខៈ នឹងហើយគាត់ធ្វើខាងអាគុយនឹងហាស

កៈ អូ្!ចឹងហោសបងណ?

ខៈ ប៉ុន្តែបាត់សូន្យជាង10ឆ្នាំហើយនឹងហាស

កៈ ចុះភរិយារបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ ប្រពន្ធរបស់ខ្ញុំរបស់ខ្ញុំនឹងបែកគ្នាហើយនឹងហាស

កៈ ប៉ុន្តែកាលពីបងការនឹងគាត់មានឈ្មោះអីគេដែរបង?

ខៈ ឈ្មោះសេង នី

កៈ ឈ្មោះ សេង នី
ប៉ុន្តែបងចាំទេថ្ងៃដែរបងរៀបអាពាហ៍ពិពាហ៍របស់បងទេគឺនៅថ្ងៃខែឆ្នាំណាដែរចឹងហាសបង?

ខៈ ចង់ភ្លេចបារ៉ូអស់ហើយបងអើយ ខ្ញុំខ្វាយខ្វល់ពេក

កៈ កូនបងរបស់បងអាយុប៉ុន្មានដែរបង?

ខៈ បងគេបង្អស់ហោសបង?

កៈ  បាទងបងគេហាស?

ខៈ  បងគេប្រហែលជាអាយុសាមសិបឆ្នាំជាងហើយនឹងហាស

កៈ  អាយុសាមសិបជាង អាយុសាមប៉ុន្មានដែរទៅ?

ខៈ  ប្រហែលជាចូលអាយុ31ឆ្នាំអីនឹងហាស

កៈ  អាយុ31ឆ្នាំចុះបងការហើយបងមានកូនភ្លាម រឺក៏យ៉ាងម៉េចដែរបង?

ខៈ  ការហើយមិនទាន់មានទេ

កៈ  ចឹងមានន័យថាបងអាយុ46ឆ្នាំ?

ខៈ  អាយុ46ឆ្នាំនឹង

កៈ  ចឹងមានន័យថាបងការអាយុ15ឆ្នាំ?

ខៈ  ខ្ញុំការប្រពន្ធរបស់ខ្ញុំអាយុ20ឆ្នាំគត់ ហើយខ្ញុំអាយុ23ឆ្នាំនឹង

កៈ  បងអាយុ23ឆ្នាំ?

ខៈ  ខ្ញុំអាយុ23 ប៉ុន្តែប្រពន្ធរបស់ខ្ញុំអាយុ20ឆ្នាំគត់

កៈ  កូនរបស់បងអាយុ22ឆ្នាំបង?

ខៈ  បាទប៉ុណ្ណឹង

កៈ  កូនរបស់បងអាយុ22ឆ្នាំទេបង?

ខៈ  បាទប្រហែលម្ភៃជាងនឹងហាស

កៈ
ចុះនៅពេលដែរបងរៀបកអាពាហ៍ពិពាហ៍នឹងគិតថាបងជាអ្នករៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយជាអ្នករៀបចំអោយដែរបង?

ខៈ  ឪពុកម្តាយជាអ្នករៀបចំអោយនឹង

កៈ  ឪពុកម្តាយណាបង ចុះបងដូចជាមានជាជំនូនអីជូនទៅប្រពន្ធរបស់បងទេ
ដូចជាមានជាថ្លៃទឹកដោះអីជូនទៅប្រពន្ធរបស់បងទេ?

ខៈ  មានជូនតាមានមាស5 ហ៊ុន

កៈ  ចុះបងចេះអាន រឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរបង?

ខ៖ បាទថាម៉េចដែរ?

ក៖ បងចេះអាន រឺមួយក៏ចេះសរសេរអក្សរខ្មែរដែរទេបង?

ខ៖ អក្សរខ្មែរយ៉ាងម៉េចវិញបង?

ក៖ ដូចជាធ្លាប់បានរៀនទេបង?

ខ៖ បានរៀនតា

ក៖ ចុះបងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី2 នឹងទី3នឹង

ក៖ ចុះកាលពីបងរៀននឹង បងរៀននៅណាដែរបង?

ខ៖ ខ្ញុំរៀននៅពារាំង

ក៖ អូ៎!នៅពារាំងនៅខេត្តព្រៃវែងនឹងហោសបង?

ខ៖ បាទនៅណុង

ក៖ ចុះបងរៀននឹងបងមានចងចាំឈ្មោះសាលាបងរៀនអត់បង?

ខ៖ នៅស្វាយប្រហូត

ក៖ នឹងបឋមសិក្សារបស់បងរៀន?

ខ៖ នឹងហើយនៅណុង

ក៖ ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរទេ ដូចជាចិន កូរ៉េ ថៃ វៀតណាម អីចឹងហាសបង?

ខ៖ អត់ចេះទេបង?

ក៖ ចុះបងចេះភាសាអីគេដែរចឹងបង?

ខ៖ ខ្ញុំចេះតែខ្មែរទេ

ក៖ បងចេះតែខ្មែរទេណបង?

ខ៖ នឹងហើយចេះខ្មែរ

ក៖ ចុះបងមានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាអត់ទេបង?

ខ៖  បាទបង?

ក៖  ចុះបងធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាហាសបង កាលពីតូចៗហាសបង?

ខ៖  មានដែរមិត្តភក្តិរាក ជ្រៅចឹងហី?

ក៖  បាទបងនឹងហើយ

ខ៖  ដល់ពេលចឹងគេមានប្តីប្រពន្ធសុខចឹងទៅ ប៉ុន្តែគេទៅគ្រួសារគេផ្សេងចឹងទៅណា

ក៖  ប៉ុន្តែបងមានណាបង?

ខ៖  មានតា

ក៖  ប៉ុន្តែបងអាចប្រាប់ឈ្មោះមួយចំនួនដែរបងចាំបានទេ?

ខ៖  ស្រលាញ់ដូចថាធ្លាប់បានរាប់អានគ្នាចឹងហាសមានច្រើនហាស

ក៖  អត់ទេបងរាប់តែមួយចំនួនបានហើយនឹងហាស?

ខ៖  ស្រលាញ់រាបអានដែរបានធ្លាប់ហូបចុកជាមួយគ្នាចឹងហាស

ក៖  បាទបងមួយចំនួនដែរបងចាំទៅបានហើយបង?

ខ៖  ឈ្មោះធូ , សែនសង្វាត

ក៖  អូ៎!ឈ្មោះ សែន សង្វាត?

ខ៖  បាទនឹងហើយ

ក៖  អត់អីទេបង ចុះបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេបង
បងមានធ្លាប់ដើរលេងកាលពីបងនៅក្មេងហាស
រឺមួយក៏បងធ្វើអីសប្បាយដែរធ្វើអោយបងចងចាំអត់ភ្លេចហាសបង?

ខ៖  គ្មានដើរអីទេ ពេលដែរយើងមានប្រពន្ធកូនហាសរាបអានគ្នានឹងមិនដែរមានអីទេ

ក៖  អូ៎!ចឹងទេហោសបង?

ខ៖  នឹងហើយគ្រាន់រាបអានគ្នាចឹងហាស

ក៖
ចុះបងគិតថាតាំងពីក្មេងហាសបងធ្លាប់ធ្វើការងារអីគេខ្លះរហូតមកដល់ឥឡូវហាសបង?

ខ៖  កាលពីនៅក្មេងស្ទូងដក

កៈ រហូតដល់ឥឡូវនឹងបងធ្វើអីគេដែរបង?

ខៈ ខ្ញុំលក់លាសនឹង

កៈ លក់លាសហោសបង?

ខៈ បាទលក់លាសនឹងតែមួយ

កៈ ចុះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្ដូរអីគេខ្លះដែរបង?

ខៈ រាល់ថ្ងៃនឹងហោស?
កៈ បាទតាំងពីក្មេងរហូតមកដល់ពេលនេះហាស
ជីវិតរបស់បងមានការផ្លាស់ប្ដូរអីគេខ្លះដែរបង?

ខៈ ផ្លាស់ប្ដូរនឹងមកពីធ្លាក់

កៈ អូ៎!ធ្លាក់?

ខៈ ផ្លាស់ប្ដូរមកលំបាកជាងមុន

កៈ ម៉េចចឹងហោស?

ខៈ ផ្លាស់ប្ដូរដូចថាលក់លាសមិនបាន ឥឡូវនឹងកំពុងតែគិងហើយនឹងហាស

កៈ អូ៎!ចឹងហោសបង?

ខៈ បាទលាសលក់ក៏មិនបាន ហើយនៅម្នាក់ឯងយប់ព្រលប់ទៀត

កៈ អូ៎!ចឹងហោសបង?

ខៈ កាលពីគាត់នៅជាមួយប្រពន្ធគាត់រកបានដែរនឹងហាស
ដល់ពេលអោយតែនិយាយពីប្រពន្ធរបស់គាត់តែងតែទឹកភ្នែក

កៈ អូ៎!យ៉ាប់ដែរ?

ខៈ ពីព្រោះគាត់បែកគ្នាជាមួយប្រពន្ធរបស់គាត់

កៈ ប៉ុន្តែម្ហូបអីគេដែរបងចូលចិត្តពិសារដែរបង?

ខៈ ម្ហូចរាល់ថ្ងៃនឹង?

កៈ បាទបងម្ហូបហាស?

ខៈ ខ្ញុំហូបធម្មតាៗនឹងហាស

កៈ ប៉ុន្តែម្ហូបអីដែរបងគិតថាចូលចិត្តជាងគេ ហើយបងតែងតែនឹកឃើញហាស?

ខៈ ម្ហូបឥឡូវនឹងហោសបង?

កៈ បាទបងចូលចិត្តជាងគេហាស?

ខៈ ឥឡូវនឹងដល់ចាស់ខ្លួនហើយអោយបងឯងសើចខ្ញុំក៏សើចទៅណាស់

កៈ អត់អីទេបង?

ខៈ មានឃ្លោកជាមួយននោង បុកជាមួយត្រីឆ្អើរនឹងយកមកស្លប្រហើរ

កៈ អូ៎!នឹងដែរបងចូលចិត្តហោស?

ខៈ បាទរឺមួយទៀតសាច់គោអាំងទៅ ជាមួយទឹកម្រេចជ្រលក់អីចឹងទៅណា

កៈ ចុះល្បែងប្រជាប្រិយ៍អីដែរបងគិតថាបងចូលចិត្តជាងគេហាស
តាំងពីក្មេងហាសបងដែរបងគិតថាបងចូលចិត្តតែម្តងហាស?

ខៈ ចូលចិត្តជាងគេ ខ្ញុំចូលចិត្តតែចំរៀងនឹងហាសអកកណ្តុង

កៈ អូ៎!អកកណ្តុងហោសបង?

ខៈ ចំរៀងអកកណ្តុង ហើយនឹងមាន់ជុល កីឡាករ នឹងគោជល់គ្នានឹង

កៈ ប៉ុន្តែបងចេះច្រៀងទេ?

ខៈ ចេះតា

កៈ បងអាចប្រាប់ចំណងជើងមួយបទដែរបងចេះច្រៀងទេ?

ខៈ ខ្ញុំច្រៀងស្រេចតែនឹកឃើញបានច្រៀងនឹងហាស

កៈ បទអីគេដែរបង?

ខៈ ថាម៉េច?

កៈ បងអាចដាក់មួយឃ្លាបានទេ?

ខៈ បានតា

កៈ អូ៎!ចឹងហោសបង បទអីគេដែរបងចូលចិត្តដែរបង?

ខៈ ខ្ញុំច្រៀងតែបទខ្ញុំខ្លួនឯងទេ

កៈ ឥឡូវនឹងបងដាក់មួយឃ្លាមកបង?

ខៈ តែច្រៀងទៅខ្លាចបងឯងខឹងខ្ញុំនឹង

កៈ អូ៎!អត់ខឹងទេបង

ខៈ អូ៎!ចឹងហោស

កៈ ខ្ញុំមានអីត្រូវខឹងបើខ្ញុំអោយបងឯងច្រៀងនឹង?

ខៈ ខ្ញុំច្រៀងតែបទកែចសារ៉ាត់ទេ

កៈ អូ៎!កែវសារ៉ាត់ពិរោះណាស់?

ខៈ ប៉ុន្តែខ្ញុំអាចចេញភ្លេងខ្លួនឯងបានទេបង?

កៈ បាទបងអត់អីទេ

ខៈ នេះគឺចំរៀង ស្រែកច្រៀងផ្តែផ្តាំហាសអើយ ជូនញ្ញាតិចូលឆ្នាំទាំងឡាយហាស មិនដែរលើទេ រាប់រយឆ្នាំខែ ឥឡូវនឹងកែប្រែដល់មករឿងខ្ញុំហាស កាលពីបងស្នេហ៍អូនញ្ញាតិមិត្តពេញចិត្តហាសអើយ សូមអូនអាណិតដល់រូបមុំផង សូមឪម៉ែពុកជាអ្នកបាចផ្កាស្លាហាសអើយ យើងបានមានកូនជាកូនជាចៅហាស ឥឡូវស្រីខ្មៅរត់ចោលគ្រួសារហាសហា លះបង់កូនចោលអោយរស់ខ្លោចផ្សារ អោយកូនឬស្សាទៅអោបសាសន៍គេហាស ឈប់យំទៅកូនជាក្បូនវាសនាហាសហា ព្រំលិខិតចារនៅមានទេ នៅមានឪមួយថ្នាក់ថ្នមមាសមេ បីបំមាសមេអោយរស់ខ្សែ

កៈ បាទអរគុណច្រើនហាសបង

ខៈ បាទមិនអីទេ

កៈ បាទបងច្រៀងពិរោះណាស់បង?

ខៈ ខ្ញុំច្រៀងពិរោះ

កៈ បងច្រៀងពិរោះហាសបង បងបើអាចឡើងច្រៀងបែបល្អ?

ខៈ ចេះតែថាម៉ង់

កៈ ខ្ញុំនិយាយមែនតាបង?

ខៈ ហ៎ា!ច្រៀងពិរោះ ខ្ញុំចេះតែរើសច្រៀងទៅតែបទណាដែរខ្ញុំចាំទេនឹងហាស

កៈ អត់អីទេបង

ខ៖ ខ្ញុំសុំទោសហាសបង

ក៖ គ្មានអីទេបង ចុះខ្ញុំសុំសួរប៉ុន្មានសំនួរទៀតចឹងហាសបង?

ខ៖ បាទៗៗសួរមក

ក៖ ចុះបងមានមិត្តភក្តិណាដែរចេះលេងឧបករណ៍ភ្លេងទេបង?

ខ៖ បាទថាម៉េច?

ក៖ បងមានមិត្តភក្តិណាដែរចេះលេងឧបករណ៍ភ្លេងទេបង?

ខ៖ ទេខ្ញុំមិនចេះទេ ខ្ញុំចង់ចេះដែរ

ក៖ ចង់និយាយពីមិត្តភក្តិហាសបង មានចេះលេងទេ?

ខ៖ ទេអត់មានទេ

ក៖ អូ៎!អត់មានទេ

ខ៖ មានតែខ្ញុំទេដែរចង់ចេះអានឹងតែម្តងនឹងហាស

ក៖
ចុះផ្ទះរបស់បងមានលក្ខណះបែបណាដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង
?

ខ៖ បាទ?

ក៖ ផ្ទះរបស់បងមានលក្ខណះបែបណាដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ផ្ទះនៅស្រែអីហោស?

ក៖ បាទបង?

ខ៖ ផ្ទះធម្មតានឹងហើយ

ក៖ ផ្ទះលក្ខណះជាផ្ទះឈើមែនទេបង?

ខ៖ ផ្ទះឈើជើងតាងយើងនឹងហាស

ក៖ បាទបង ចុះនរណាគេជាអ្នកសាងសងផ្ទះមួយនឹងដែរបង?

ខ៖ សាងសងប្តីប្រពន្ធទាំងអស់គ្នា ដូចថាយើងរកស៊ីពីមុនមកហាស

ក៖ ប៉ុន្តែនរណាគេជាអ្នកធ្វើដែរបង ដូចជាបងជួលគេរឺមួយក៏បងធ្វើដោយខ្លួនឯងដែរបង?

ខ៖ ខ្ញុំជួលគេដែរនឹង

ក៖ អូ៎!បងជួលគេហោស?

ខ៖ បាទជួល

ក៖ ចុះបងគិតថាផ្ទះរបស់បងធ្វើនឹងគេប្រើឧបករណ៍អីគេខ្លះសំរាប់ធ្វើវាទេបង?

ខ៖ មើលចាំ

ក៖ បងគិតថាផ្ទះបងគេប្រើឧបករណ៍អីគេខ្លះសំរាប់ធ្វើវាដែរទេបង?

ខ៖ មានញញួរ ពូថៅ

ក៖ បាទបាទបងមានអីទៀតបង?

ខ៖ មានដែកគោល មានរនាប

ក៖ មានឈើអីចឹងហាសណាបង?

ខ៖ មានឈើអីចឹងទៅ មានត្នោតកាលណុងធ្វើត្នោត ត្នោតនៅខាងកំពង់ស្ពឺ

ក៖ ចុះបងគិតថាជំនាញអីដែរបងគិតថាបងចេះស្ទាត់ជំនាញដែរបង?

ខ៖ ចេះស្ទាត់

ក៖ ដូចជាជំនាញលក់លាស រឺក៏ជំនាញអីមួយដែរបងគិតថាបងចេះស្ទាត់តែម្តងហាសបង?

ខ៖ នឹងហើយខ្ញុំតែលក់លាស លក់នុំ ធ្វើស្រែធ្វើអីនឹងតែប៉ុណ្ណឹង

ក៖ ប៉ុន្តែបងចេះលក្ខណះថា កូស្ករ វេញវល្លិ៍ ធ្វើផ្តៅ ធ្វើកន្ទេល រឺត្បាញក្រម៉ាអីដែរទេបង?

ខ៖ មិនដែរផង

ក៖ ការងាររាល់ថ្ងៃចំណូលចូលចិត្តធ្វើអីគេដែរ?

ខ៖ បើនៅស្រែបើមិនមានអីលក់មានតែស្ទូងដកនឹងហើយ

ក៖ អូ៎!ចឹងហោសបង?

ខ៖ ដល់ពេលដែរយើងមកភ្នំពេញចឹង យើងមានចំណូលអីមានតែលក់លាស
នឹងលក់នុំនឹងហាសមានតែប៉ុណ្ណឹង

ក៖ អូ៎!ល្អហើយចឹងបង?

ខ៖ មានទៅល្អចប្អូនណា

ក៖ ចុះបងអាចប្រាប់ពីពេលណាដែរបងគិតថាជាពេលដែរលំបាកនៅក្នុជីវិតរបស់បងបានទេបង?

ខ៖ បាទថាម៉េចដែរ

ក៖ ចុះបងអាចប្រាបថាពេលណាដែរបងគិតថាជាពេលដែរពិបាកជាងគេនៅក្នុងឆាកជីវិតរបស់បងដែរហាស?

ខ៖ ពិបាកជាងគេខ្ញុំពិបាកណាស់

ក៖ ពេលណាដែរបង?

ខ៖ ពិបាកដកស្ទូង ឡើងពីយប់ ឡើងដាក់ស្មៅពីយប់ដាក់អោយគោស៊ី ព្យូរអីចឹងហាស

ក៖ មានអីផ្សេងទៀតទេបង?

ខ៖ យ៉ាប់ហាស ដល់ពេលដែរនិយាយទៅប្រវត្តិពិបាកបងអើយ

ក៖ ចឹងហោសបង?

ខ៖ តែខ្ញុំនិយាយទៅខ្លាចហូរទឹកភ្នែក ថាខ្ញុំច្រៀងមិញនឹងខ្ញុំចេះច្រៀង បើខំអីនឹងបងឯងកាត់ពិន្ទុខ្ញុំហើយនឹងហាស

ក៖ អូ៎!អត់អីទេបង រឿងគាត់តា

ខ៖ មែនហោសបង?

ក៖ បាទបង បើលើកក្រោយបើបងឯងដាក់នៅcambodian idol បែបល្អហាសបង?

ខ៖ បាទមែន?

ក៖ ចុះបងឯងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរបង?

ខ៖ លំបាកយ៉ាងម៉េចដែរបង?

ក៖ ឆ្លងកាត់វាដោយវិធីណា?

ខ៖ ថានៅជាមួយម្ដាយទៅពិបាក ដល់ពេលដែរមានប្រពន្ធនឹងពិបាកទៀតនឹងហាស ប្រពន្ធមានរឿងរ៉ាវទៀតនឹងហាសផិត ក្បត់ទៅចោលទៀតនឹងហាស

កៈ បាទបង ចុះពេលណាដែរបងគិតថាសប្បាយជាងគេនៅក្នុងឆាក

កៈ អូ្ន!ជួបជុំក្រុមគ្រួសារណាបង?

ខៈ នឹងហើយបើមិនបានជួបគ្នាមិនពិបាកចិត្ត

កៈ បាទបងចុះកាលពីក្មេងបងធ្លាប់មានក្តីស្រម៉ៃថាបងចង់ធ្វើអីគេដែរទេបង?

ខៈ កាលពីក្មេង

កៈ បាទបងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងបងចង់ធ្វើអីគេមដែរទេបង?

ខៈ ក្តីស្រម៉ៃខ្ញុំចង់តែច្រៀង ចង់តែអកកណ្តុង ច្រៀងលេងអោយសប្បាយអីចឹងទៅណាស់ ចង់ច្រៀងលេងសប្បាយ

កៈ អូ្ន!ចឹងហោសបង?

ខៈ បាទឃើញខ្ញុំចេះតែច្រៀងលេងទេ ខ្ញុំមិនប៉ះពាល់បងប្អូនមួយណាទេបង

កៈ បាទបងអត់អីទេបង?

ខៈ ខ្ញុំច្រៀងមិញសុំទោសបង

កៈ ចុះបើចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗហាស តើបងចង់ផ្តែផ្តាំអីគេខ្លះដែរទៅពួកគាត់ដែរបង?

ខៈ ក្មេងសារក្រោយហោស?

កៈ ទាំងក្មេងកូនបងអីនឹងហាស ទាំងបងប្អូនជិតស្និទ្ធអីចឹងហាសបង?

ខៈ ខ្ញុំសំណូមពរដល់កូនចៅជំនាន់ក្រោយៗទៀតនឹង អោយរៀនចេះដឹង អោយចេះយល់ពីម្តាយឪពុក អោយរៀនអីអោយច្បាស់ៗនឹងហាស អោយចេះគោរពចាស់ទុំ ហើយនឹងមុខរបរធ្វើអីអោយបានល្អនឹងហាស

កៈ បាទបងចឹងមានអីទៀតទេ?

ខៈ នឹងហើយបងកុំអោយក្មេងៗវាឈ្លើយ កុំអោយចាស់ៗដូចខ្ញុំចឹងទៅណាស់ អោយចេះដឹង នឹងមើលគេមើលឯង មានអីហូបនឹង នឹងជូនចាស់ទុំ កុំអោយឈ្លើយ អោយស្អាតស្អំ កុំអោយដូចឥឡូវនឹងពិបាកណាស់

កៈ បាទបងមានអីផ្សេងដែរបងចង់ផ្តែផ្តាំទៀតទេបង?

ខ៖ ចង់អោយកូនក្មួយទាំងអស់នឹងអោយខំរកស៊ីនឹងធ្វើបុណ្យធ្វើទាន
កុំអោយពិបាកដូចជាតិណាទៀត

ក៖ បាទបងត្រូវហើយបង?

ខ៖ អោយចេះគោរពចាស់ទុំដូចសារដើមចឹងហាស

ក៖ បាទបងបាទ

ខ៖ អោយចេះស្គាល់ពូ ស្គាល់មីងមា ស្រលាញ់អីយើងធ្វើការងារនឹងទៅ

ក៖ បាទបងត្រូវហើយ?

ខ៖ ធ្វើអីអោយដឹងការងារណុង

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំអាច
ដូចជាពិភាក្សាជាមួយបងដែរទាក់ទងពីប្រវត្តិរបស់បងហាស
ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរចឹងហាសបង
ដើម្បីតំកល់ទុកអោយបងចឹងហាស
ចឹងហើយខ្ញុំនឹងយកជាឌីសមួយអោយបងដើម្បីអោយបងអាចអោយកូនចៅជំនាន់ក្រោយ
ៗបងអាចបានស្គាល់ពីប្រវត្តិរបស់បង នឹងឪពុកម្តាយជីដូនជីតាចឹងហាសបង
ដែរបងបានរៀបរាប់ប្រាប់ខ្ញុំមិញចឹងហាសបង បាទអរគុណច្រើនបង៕៕៕